ភ្នំពេញ ថ្ងៃទី ២០ ខែមេសា ឆ្នាំ២០១៧

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

# កិច្ចប្រជុំបូកសរុបលទ្ធផល ប្រមូលចំណូលពន្ធ ប្រចាំខែមីនា និងប្រចាំត្រីមាសទី១ ឆ្នាំ២០១៧ របស់អគ្គនាយកដ្ឋានពន្ធដារ




*© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ*

នាវេលាម៉ោង ០៩:០០ នាទីព្រឹក ថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៧ នៅអគ្គនាយកដ្ឋានពន្ធដារមានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលគ្រប់គ្រងប្រមូលចំណូលពន្ធប្រចាំខែមីនា និងប្រចាំត្រីមាសទី១ ឆ្នាំ២០១៧ របស់អគ្គនាយកដ្ឋានពន្ធដារ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមទេសរដ្ឋមន្ត្រី **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងវត្តមានចូលរួមរបស់ ឯកឧត្តម **ជូ ចិវិត្ត** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ និងវត្តមានចូលរួមជាកិត្តិយស របស់ឯកឧត្តម អគ្គនាយក-អគ្គនាយករង នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋាន គោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំង ឯកឧត្តម-លោកស្រីអគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ លោកប្រធាន-អនុប្រធាននាយកដ្ឋាន លោកប្រធានសាខាពន្ធដារខេត្ត-ខណ្ឌទាំងអស់ ក្រោមចំណុះអគ្គនាយកដ្ឋានពន្ធដារ។

ជាកិច្ចចាប់ផ្តើម ឯកឧត្តម គង់ វិបុល ប្រតិភូរាជរដ្ឋាភិបាល បានសម្តែងនូវកិច្ចស្វាគមន៍យ៉ាងកក់ក្តៅ ចំពោះវត្តមានឯកឧត្តម



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

ទេសរដ្ឋមន្ត្រី ដែលបានផ្ដៀតឱកាសដ៏មានតម្លៃ និងមមាញឹកពីការងារ ចូលរួមជាគណៈអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលគ្រប់គ្រងប្រមូលចំណូលពន្ធ ប្រចាំត្រីមាសទី១ ឆ្នាំ២០១៧របស់អគ្គនាយកដ្ឋានពន្ធដារ។តាមរយៈរបាយការណ៍របស់ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលបង្ហាញថា លទ្ធផលប្រមូលចំណូលពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ ទទួលបានលទ្ធផលល្អ គួរជាទីមោទនៈ។

សម្រាប់ខែមីនា ឆ្នាំ២០១៧ អគ្គនាយកដ្ឋានពន្ធដារប្រមូលពន្ធ-អាករគ្រប់ប្រភេទ បានចំនួន ១ ៦៦៨ ១៧៦,៧៩ លានរៀល (ប្រមាណជា ៤១៧,០៤ លានដុល្លារ)។

សម្រាប់ត្រីមាសទី១ ឆ្នាំ២០១៧ ចំណូលពន្ធ-អាករគ្រប់ប្រភេទ ដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបាន មានចំនួន ៣ ០៧៤ ពាន់លានរៀល (ប្រមាណជា ៧៦៨,៦២ លានដុល្លារ) ស្មើនឹង ៤៤,៨០ % នៃផែនការ។ ប្រសិនបើប្រៀបធៀបនឹងរយៈពេលដូចគ្នា នៃឆ្នាំ២០១៦ ឃើញថា ការអនុវត្តប្រមូលចំណូលពន្ធ-អាករគ្រប់ប្រភេទសម្រាប់ត្រីមាសទី១ ឆ្នាំ២០១៧ កើនឡើងចំនួន ១ ៤៧៤,៨៤ ពាន់លានរៀល (ប្រមាណ ៣៦៨,៧១ លានដុល្លារ) ឬស្មើនឹងអត្រាកំណើន ៩២,២០ %។

ក្នុងត្រីមាសទី១ ឆ្នាំ២០១៧ នេះ អគ្គនាយកដ្ឋានពន្ធដារសង្កេតឃើញថា មានការកើនឡើងផងដែរនូវចំណូលពន្ធ-អាករតាមប្រភេទពន្ធ និងសកម្មភាពអាជីវកម្មសំខាន់ៗមួយចំនួនដូចជា៖ ពន្ធលើប្រាក់ចំណូល កើនឡើង ៤០,៦០%, ពន្ធលើប្រាក់បៀវត្ស កើនឡើង ៤៩,៤០%, អាករលើតម្លៃបន្ថែម កើនឡើង ៨០,៧០%, និងអាករពិសេស កើនឡើង ១៧,១២%។ ចំណែកឯចំណូលពន្ធ-អាករ តាមសកម្មភាពអាជីវកម្ម ក៏មានការកើនឡើង ស្ទើរគ្រប់ប្រភេទអាជីវកម្មផងដែរ ពិសេសវិស័យផលិតយានយន្ត, វិស័យកសិកម្ម, វិស័យស្រាវជ្រាវ និងរុករករ៉ែ, វិស័យសិក្សាអប់រំ ។ល។

លទ្ធផលយ៉ាងល្អប្រសើរដែលទទួលបាននេះ ដោយសារការចង្អុលបង្ហាញណែនាំដ៏ខ្ពង់ខ្ពស់ ពីឯកឧត្តមទេសរដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏ដូចជាថ្នាក់ដឹកនាំដទៃទៀត អគ្គនាយកដ្ឋានពន្ធដារ ក្រោមការដឹកនាំរបស់ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ បានអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវតួនាទី និងភារកិច្ចរបស់ខ្លួនស្របតាមយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ និងកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ព្រមទាំងការ ព្រមទាំងច្បាប់និងបទប្បញ្ញត្តិស្ដីពីពន្ធដារ ដែលក្នុងនោះអគ្គនាយកដ្ឋានពន្ធដារបានអនុវត្តការងារកែទម្រង់ (១) រដ្ឋបាលសារពើពន្ធ ជាអាទិ៍ ការចុះបញ្ជីអ្នកជាប់ពន្ធ, ការផ្ដល់សេវាអ្នកជាប់ពន្ធ, ការចាត់ចែងលិខិតប្រកាស, ការធ្វើសវនកម្ម, ការប្រមូលបំណុលពន្ធនិងបណ្ដឹងតវ៉ា, ការពង្រឹងការគ្រប់គ្រង និងរចនាសម្ព័ន្ធ ការគ្រប់គ្រងធនធានមនុស្ស, និង (២) គោលនយោបាយសារពើពន្ធ។


© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ


© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

បន្ទាប់ពីស្តាប់របាយការណ៍លម្អិត យ៉ាងក្បោះក្បាយគ្រប់ជ្រុងជ្រោង ស្ទើរគ្រប់ផ្នែកទាំងអស់ ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានអង្គប្រជុំ បានសម្តែងនូវមូលវិចារដ៏ថ្លៃថ្លា វាយតម្លៃខ្ពស់ និងកោតសរសើរចំពោះឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការពន្ធដារគ្រប់លំដាប់ថ្នាក់ ដែលបានខិតខំប្រឹងប្រែងប្រមូលចំណូលពន្ធប្រកបដោយប្រសិទ្ធភាព ពិសេសការសម្រេចបាននូវលទ្ធផលប្រមូលចំណូលពន្ធលើប្រាក់ចំណូល ដែលមានការកើនឡើងយ៉ាងខ្លាំង និងការទទួលបាននូវប្រតិកម្មជាវិជ្ជមានពីអ្នកជាប់ពន្ធ ចំពោះការផ្តល់សេវារបស់អគ្គនាយកដ្ឋានពន្ធដារគឺមានភាពងាយស្រួល និងរហ័សជាងមុន ដែលឆ្លុះបញ្ចាំងអំពីការខិតខំប្រឹងប្រែងក្នុងការប្រមូលចំណូល និងកំណែទម្រង់កន្លងមកនេះ។ ឯកឧត្តមទេសរដ្ឋមន្ត្រីមានសេចក្តីសង្ឃឹមថាលទ្ធផលប្រមូលចំណូលពន្ធក្នុងឆ្នាំ២០១៧ នឹងទទួលបានលទ្ធផលល្អប្រសើរបន្ថែមទៀត តាមរយៈការពិនិត្យមើល លើសន្ទុះនៃការប្រមូលចំណូលពន្ធក្នុងត្រីមាសទី១ ឆ្នាំ២០១៧ នេះ។

ឆ្លៀតក្នុងឱកាសនេះដែរ ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រធានអង្គប្រជុំ បានសម្តែងនូវការគាំទ្រ និងឯកភាពទាំងស្រុងចំពោះវិធានការនានា ដែលបានដាក់ចេញដោយ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ក្នុងន័យបង្កើនផលិតភាព ក៏ដូចជា ការធ្វើទំនើបកម្មរដ្ឋបាលសារពើពន្ធ និងកម្មវិធីកែទម្រង់ ក៏ដូចជាការធ្វើទំនើបកម្មរដ្ឋបាលសារពើពន្ធ ជាពិសេសការពិនិត្យកែសម្រួល និងរៀបចំ លិខិតបទដ្ឋានគតិយុត្តនានា ដើម្បីធានាការអនុវត្តការងារគ្រប់គ្រងប្រមូលពន្ធប្រកបដោយសង្គតិភាព និងដោយរលូន។

ជាទីបញ្ចប់ ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រធានអង្គប្រជុំ បានវាយតម្លៃខ្ពស់ និងថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅ ព្រមទាំងជូនពរសព្វសាធុការក្នុងឱកាសឆ្នាំថ្មីនេះ ដល់ថ្នាក់ដឹកនាំគ្រប់អង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានពន្ធដារ ដែលបាននិងកំពុងចូលរួមយ៉ាងសកម្ម ក្នុងការខិតខំប្រឹងប្រែងប្រមូលចំណូលរហូតទទួលបានលទ្ធផលយ៉ាងល្អប្រសើរ។ ទន្ទឹមនឹងនេះ ឯកឧត្តមទេសរដ្ឋមន្ត្រី ក៏បានផ្តល់ការណែនាំបន្ថែមដល់គ្រប់អង្គភាព ឱ្យបន្តខិតខំពង្រឹងការអនុវត្តច្បាប់ វិន័យការងារ និងត្រូវមានភាពទន់ភ្លន់ម៉ឺងម៉ាត់ ក្នុងការឆ្លើយតបទៅកាន់អ្នកជាប់ពន្ធ ធ្វើយ៉ាងណាឱ្យអ្នកជាប់ពន្ធសប្បាយចិត្ត មិនសម្តែងការរអ៊ូរទាំ និងផ្តល់កិច្ចសហការល្អក្នុងការបង់ពន្ធជូនរដ្ឋ៕



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ


© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ


© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ


© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ